# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការប្រជាជន
លេខ ៧១៤ តប្រក

# ប្រធានតុលាការប្រជាជនកំពូល

**ជម្រាបមក**

**លោកប្រធានតុលាការប្រជាជន ខេត្តបាត់ដំបង់**

**កម្មវត្ថុ:** ការអនុវត្តច្បាប់ ស្តីពីការដាក់គុកបង្ខំដល់រូបកាយក្នុងរឿងព្រហ្មទណ្ឌ និង ច្បាប់ស្តីពីនីតិវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី ។

**យោង:** លិខិតលេខ ៥៥៤ តក-២ ចុះថ្ងៃទី១៣-០៧-៩២ របស់តុលាការប្រជាជនខេត្តបាត់ដំបង ។

តមនិងលិខិតដូចមាន យោងខាងលើ ខ្ញុំសូមជម្រាបលោកដូចតទៅនេះ៖

១-ច្បាប់ស្តីពីនីតិវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី ប្រកាសឲ្យប្រើតាមក្រឹត្រលេខ ៥១ ក្រ ចុះថ្ងៃទី០២-០៥-៩២ នឹងច្បាប់ស្តីពីការដាក់គុកបង្ខំដល់រូបកាយក្នុងរឿងព្រហ្មទណ្ឌ ប្រកាសឲ្យប្រើតាមក្រឹត្យលេខ ១៨ ក្រ ចុះថ្ងៃទី ០៨-០២-៩២ ពុំមានចែងក្នុងអវសានបញ្ញាត្តិ នូវអានុភាពប្រតិកម្មនៃច្បាប់នោះឡើយ ។ ដូចនេះតុលាការក្តី អ្នកអនុវត្តសាលក្រមក្តី មិនត្រូវយកច្បាប់នេះទៅអនុវត្តលើសាលក្រមស្ថាពរ ទាំងឡាយណាដែលចេញមុនដែលច្បាប់ទាំងពីនេះចូលជាធរមានបានឡើយ មានន័យថាចំពោះសាលក្រម ត្រូវអនុវត្តតាមសេចក្តីណែនាំរបស់ក្រសួងយុត្តិធម៌បានធ្វើកន្លងទៅហើយនោះ ។

២-ការដាក់គុកបង្ខំលើរូបកាយ គឺជាវិធានការបង្ខំទណ្ឌិតឲ្យសងធនទណ្ឌ (មាត្រា ៣ ច្បាប់ស្តីពីការដាក់គុកបង្ខំដល់រូបកាយក្នុងរឿងព្រហ្មទណ្ឌ)។ការដាក់គុកបង្ខំនេះ ជាវិធានការដោយឡែកដែលមិនអាចចាត់បញ្ចូលជាមួយទណ្ឌកម្មដាក់គុកក្នុងរឿងអង្គសេចក្តីនោះឡើយ ។ យ៉ាងណាមិញក្នុងពេលមានសាលក្រមស្ថាពរសម្រេចផ្តន្ទាទោសដាក់គុក ប៉ុន្តែទោសគុកនោះត្រូវព្យួរទោស នោះទណ្ឌិតត្រូវបានរស់នៅក្រៅគុកជួបជុំគ្រួសារជាធម្មតា ។នៅក្នុងរយៈកាលសាកល្បងនៃការព្យួរទោ ការដាក់គុកបង្ខំលើរូបកាយដើម្បីទារធនទណ្ឌអាចអនុវត្តបាន ។

ដូចនេះ បើដើមបណ្តឹងរដ្ឋប្បវេណីប្តឹងសុំឲ្យទារសំណងនិងជម្ងឺចិត្ត អ្នកអនុវត្តសាលក្រមត្រូវទៅទារប្រាក់ពីទណ្ឌិតតាមរបៀបនៃការទារប្រាក់សំណងនិងជម្ងឺចិត្ត ក្នុងរឿងរដ្ឋប្បវេណីជាមុនសិន(មាត្រា ២ នៃច្បាប់ខាងលើនេះ) ទើបអនុវត្តវិធីដាក់គុកបង្ខំលើរូបកាយបាន មានន័យថាអ្នកអនុវត្តសាលក្រមត្រូវ៖

ទី១-ទារប្រាក់សំណង និងជម្ងឺចិត្ត

ទី២-បើគ្មានប្រាក់សង ទើបរឹបអូសទ្រព្យសម្បត្តិលក់ឡាយឡុងយកប្រាក់សង

ទី៣-បើធនធានលក់ឡាយឡុងសងមិនគ្រប់ ទើបចាត់វិធានការដាក់គុកបង្ខំលើរូបកាយ ។

**កំណត់សម្គាល់** តុលាការនិងអ្នកអនុវត្តសាលក្រម មិនត្រូវច្រឡំការដាក់គុកបង្ខំលើរូបកាយក្នុងរឿងព្រហ្មទណ្ឌជាមួយការដាក់គុកបង្ខំលើរូបកាយ ក្នុងរឿងរដ្ឋប្បវេណីឡើយ ។

ក្នុងរឿងរដ្ឋប្បវេណី តុលាការសម្រេចដាក់គុកបង្ខំលើរូបកាយបាន លុះត្រាតែដើមចោទប្តឹសុំក្នុងពាក្យបណ្តឹងក៏បាន ប្តឹងសុំដោយមាត់ទទេនៅពេលសវនាការក៏បាន (មាត្រា ១២៨ ច្បាប់ស្តីពីវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី) ។

រីឯក្នុងរឿងព្រហ្មទណ្ឌវិញរូបមន្តដាក់គុកបង្ខំលើរូបកាយ ត្រូវសរសេរក្នុងសេចក្តីសម្រេចនៃសាលក្រមតែម្តង ។ ជូនជាប់ជាមួយ ៖

-គំរូនៃសេចក្តីសម្រេច.........................................................................................................០១ច្បាប់ ។

ខ្ញុំសង្ឃឹមថា សេចក្តីខាងលើនេះនិងញុំាងឲ្យតុលាការនិងអ្នកអនុវត្តសាលក្រមអាចចាត់ការរបស់ខ្លួនបានពិតប្រាកដ ។កាលបើមានការស្រពិចស្រពិលត្រង់ចំណុចណានោះ នោះអាចលើកជាសំណួរមកតុលាការប្រជាជនកំពូលទៀតបាន ។

ធ្វើនៅភ្នំពេញ ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ១៩៩២

**ហត្ថលេខា និងត្រា**

**ចាន់ សុក**

ចម្លងជូន

-រដ្ឋសភា

-មហាអយ្យការតុលាការ អមតុលាការប្រជាជនកំពូល

-ក្រសួងយុត្តិធម៌

-គ្រប់តុលាការខេត្តក្រុង

-កាលប្ប វត្តិ

-ឯកសារ